## ព្រឹត្តិបត្របច្ចេកទេស លេខ ៥៤

# ការប្រើប្រាស់ឧបករណ៍ព្រោះស្រូវ

សូមអនុវត្តតាមការណែនាំខាងក្រោម ដើម្បីអោយការប្រើប្រាស់ឧបករណ៍ព្រោះពូជស្រូវ ដោយប្រើពូជដែលបានបណ្ដុះទុកជាមុនទទួលបានជោគជ័យ៖

១. ផ្ទើមដីនៅក្នុងស្រែអោយទៅជាភក់និងពង្រាបអោយស្មើល្អ (សូមមើលរូបខាងឆ្វេង)

២. បង្ហូរទឹកដែលលើសចេញពីស្រែមុនពេលព្រោះ ប៉ុន្តែកុំទុកអោយផ្ទៃខាងលើស្ងួត (សូមមើលរូបខាងស្ដាំ)





៣. បណ្ដុះពូជស្រូវជាមុន សូមកុំទុកអោយពូជស្រូវដុះពន្លកវែងពេក ជាធម្មតា រយៈពេល២៤ម៉ោងគឺគ្រប់គ្រាន់សម្រាប់ការបណ្ដុះ ។



ពន្លកវែងពេកអាចនឹងងាយខូច



គ្រាប់ស្រូវមិនដុះនឹងមានដំណុះខ្សោយ



ពន្លកដែលទើបតែដុះចេញពីគ្រាប់ដែលបានបណ្ដុះ

៤. ហាលសម្ងួតពូជស្រូវដែលដុះពន្លកនៅក្នុងម្លប់ ពី១៥ ទៅ ២០នាទី មុនពេលព្រោះដើម្បីញែកគ្រាប់ពូជ






៥. ព្រោះគ្រាប់ស្រូវដោយប្រើឧបករណ៍ព្រោះស្រូវ

ក. សូមកុំដាក់គ្រាប់ស្រូវក្នុងបំពង់អោយលើសពី២ភាគ៣

ខ. អូសឧបករណ៍ដោយដើរអោយហ្មឹង (ឯកសណ្ឋានភាពគឺជាការសំខាន់)


ស្រែដែលពង្រៀបបានល្អនិងបានបង្ហូរទឹកចេញ


ស្រែពង្រៀបពមិនបានល្អ គ្រាប់ពូជនឹងធ្លាក់ យឺតហើយគរគ្នានៅកន្លែងខ្លះ

៦. ផ្អាកស្រោចទឹក ពី ២ ទៅ ៣ថ្ងៃ ដើម្បីអោយឬសរឹងមាំ ។ សូមប្រយ័ត្នប្រយែងថែទាំក្នុងរដូវវស្សា ព្រោះទឹកភ្លៀងដែលធ្លាក់បន្ទាប់ពីការព្រោះស្រូវហើយភ្លាមៗ អាចនឹងហូរនាំគ្រាប់ពូជដែលទើបនឹងព្រោះថ្មីៗទៅអស់ ។



៧. បង្កើនជម្រៅទឹកបន្តិចម្តងៗខណៈដែលសំណាបលូតលាស់ ប៉ុន្តែមិនត្រូវពន្លិចសំណាបទាំងស្រុងទេ ។





៨. អាចបង្កើនការពន្លិចទឹកពេលដែលសំណាបលូតលាស់ ដើម្បីគ្រប់គ្រងស្មៅបានល្អ ។



**កម្ពុជាហាវែស**
ផ្ទះលេខ ៤៦ ផ្លូវ ៣១០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន
ក្រុងភ្នំពេញ
ទូរស័ព្ទ ០២៣ ៩៩៦ ៤១៩
harvest@fintrac.com

ព្រឹត្តិបត្រនេះរៀបចំឡើងក្រោមការឧបត្ថម្ភពីប្រជាពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)។

ខ្លឹមសារនៅក្នុងឯកសារនេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុនហ្វីនត្រាក់ Fintrac Inc. និងមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬ រដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។